# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល

## ស្តីពី

## ការរកឃើញករណីថ្មី វិជ្ជមានវីរុសកូវីដ១៩ ចំនួន ០៤ នាក់

## និង អ្នកព្យាបាលជាសះស្បើយ ចំនួន ០២ នាក់

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. សរុបស្ថានភាពជំងឺកូវីដ១៩ នៅទូទាំងប្រទេស៖**

ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ១៩ មានដូចតទៅ៖

- អ្នកព្យាបាលជាសះស្បើយសរុបចំនួន **២៣នាក់** (បុរសជនជាតិចិន ០១នាក់ ស្ត្រីជនជាតិអង់គ្លេស ០២នាក់ បុរសជនជាតិអង់គ្លេស ០១នាក់ បុរសជនជាតិបារាំង ០១នាក់ និងបុរសជនជាតិខ្មែរ ១៨នាក់) គិតចាប់ពីខែមករាដល់បច្ចុប្បន្ននេះ (ស្មើនឹង ២១,៥ % ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ១៩ទាំងអស់)
- អ្នកដែលកំពុងសម្រាកព្យាបាល សរុបចំនួន **៨៤នាក់** (ស្ត្រី ២៧នាក់ និងបុរស ៥៧នាក់) នៅតាមមន្ទីរពេទ្យរដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត
- អ្នកមានវីរុសកូវីដ១៩ ដែលបានរកឃើញទាំងអស់ (រាប់ទាំងអ្នកដែលបានព្យាបាលជាសះស្បើយ និងអ្នកដែលកំពុងព្យាបាល) នៅទូទាំងប្រទេស សរុបចំនួន **១០៧នាក់** (ស្ត្រី ២៩នាក់ និងបុរស ៧៨នាក់)។

**២. ករណីជាសះស្បើយចំនួន ០២ករណី មានដូចតទៅ៖**

បុរសអាយុ ៣៨ឆ្នាំ (ជាអ្នកដែលបានឆ្លងជំងឺកូវីដ១៩ពីបុរសជនជាតិជប៉ុន) នៅខេត្តសៀមរាប និងបុរសអាយុ ៣៥ឆ្នាំ នៅខេត្តបន្ទាយមានជ័យ បានព្យាបាលជាសះស្បើយ ដោយមានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ១៩ ចំនួន ០២ លើក។ បុរសទាំងពីររូបនេះ ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យនៅថ្ងៃនេះ។

**៣. ករណីវិជ្ជមានវីរុសកូវីដ១៩ ចំនួន ០៤ នាក់ (ជនជាតិបារាំង ០១ និង ខ្មែរ ០៣) មានដូចតទៅ៖**

- បុរសជនជាតិខ្មែរ អាយុ ៣០ឆ្នាំ នៅភូមិប្រជាធម្ម សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ជាអ្នកបម្រើការនៅកាស៊ីណូនិងកាហ្វេអូខេមួយនៅច្រកប៉ោយប៉ែត មានវិជ្ជមានវីរុសកូវីដ១៩ ដែលត្រូវបានដាក់ឲ្យព្យាបាលនៅមន្ទីរពេទ្យខេត្តបន្ទាយមានជ័យ
- បុរសជនជាតិខ្មែរ អាយុ ៣៦ឆ្នាំ នៅឃុំតាអុង ស្រុកចំការលើ ខេត្តកំពង់ចាម មានវិជ្ជមានវីរុសកូវីដ១៩ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ បុរសរូបនេះ ជាអ្នកដំណើរវិលត្រឡប់មកពីប្រទេសជប៉ុន មកដល់កម្ពុជានៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២០

- ស្ត្រីជនជាតិខ្មែរ អាយុ ២០ឆ្នាំ នៅសង្កាត់អូឬស្សី១ ខណ្ឌ៧មករា រាជធានីភ្នំពេញ មានវិជ្ជមានវីរុសកូវីដ១៩ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ ស្ត្រីរូបនេះ ជានិស្សិតខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសអង់គ្លេស មកដល់កម្ពុជានៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២០
- បុរសជនជាតិបារាំងអាយុ ៦១ឆ្នាំ នៅទួលទំពូង រាជធានីភ្នំពេញ មានប្រវត្តិធ្វើដំណើរទៅប្រទេសហ្គុយយ៉ាណា (GUYANA) មកដល់កម្ពុជានៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២០ មានវិជ្ជមានវីរុសកូវីដ១៩ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាព ដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃចន្ទ ០៧កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០២០

និន្នាការនៃចំនួនវិជ្ជមានកូវីដ ១៩ សរុបទូទាំងប្រទេសតាមថ្ងៃជូនព័ត៌មាន




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០២០

## ចំនួនករណី វិជ្ជមានកូវីដ ១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត

## សរុប ១០៧ ករណី




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០២០

### ចំនួនករណីវិជ្ជមានកូវីដ ១៩ ថ្មីដែលបានរកឃើញប្រចាំថ្ងៃ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០២០




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃ ២៩ ខែមីនា ឆ្នាំ២០២០

## ករណីវិជ្ជមានកូវីដ ១៩ បែងចែកតាមភេទ
## ក្នុងចំណោម ១០៧ ករណី




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០២០

## ចំនួនករណីវិជ្ជមានកូវីដ ១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត

## សរុប ១០៧ ករណី




ប្រភព៖ ក្រសួងសុខាភិបាល